# លក្ខខណ្ឌយោង

តួនាទីៈ ទីប្រឹក្សាបច្ចេកទេស

ទីកន្លែងបម្រើការងារៈ Freelancer

## I. សាវតារ

1. នៅក្នុងខែធ្នូ ឆ្នាំ២០០៤ រាជរដ្ឋាភិបាលកម្ពុជា(RGC) បានអនុម័តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) ដែលជាកម្មវិធីកំណែទម្រង់រយៈពេលវែងដោយផ្អែកលើវិធីសាស្ត្រ ដំណាក់កាល ដែលដោះស្រាយបញ្ហាប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។ ចាប់តាំងពីពេលចាប់ផ្តើមរបស់ខ្លួន កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានផ្តល់លទ្ធភាពឱ្យកម្ពុជា សម្រេចបាននូវការរីកចម្រើនយ៉ាងសំខាន់ក្នុងការធ្វើការកែទម្រង់គោលនយោបាយចំណាយសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ។

2. ដំណាក់កាលទីមួយក្នុងរយៈពេល៦ឆ្នាំកន្លងមកនេះ បានធ្វើឱ្យមានសុពលភាពនូវវិធីសាស្ត្រ និងជាជំហាន។ ពន្ធលើប្រាក់ចំណូលរដ្ឋបាលត្រូវបានពង្រឹងយ៉ាងរឹងមាំ ដូចជាមានការរៀបចំថវិកា និងការគ្រប់គ្រងបរិយាប័ន្ន វិន័យសារពើពន្ធ និងការគ្រប់គ្រងបំណុល។

3. បើទោះបីជាមានការយឺតជាងការរំពឹងទុកសម្រាប់ការចាប់ផ្តើមអនុវត្តកម្មវិធីក្នុងដំណាក់កាលទីពីរ (ដែលបានចាប់ផ្តើមក្នុងឆ្នាំ២០០៩) កិច្ចខិតខំប្រឹងប្រែងត្រូវបានបង្កើនឡើងយ៉ាងខ្លាំងក្នុងរយៈពេលពីរឆ្នាំដើម្បីបង្កើនគណនេយ្យភាពហិរញ្ញវត្ថុស្ថិតនៅក្រោមការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃគម្រោងគណនេយ្យភាព (PFMAP)។ ភាគច្រើននៃគោលការណ៍អនុត្តការងារផ្អែកទៅលើកាតាលីករពាក់ព័ន្ធគ្នាចំនួនប្រាំដែលផ្តោតលើការអនុវត្ត FMIS ដែលមានចែងនៅក្នុងយុទ្ធសាស្ត្រអាទិភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (MEF) នឹងបានគាំទ្រដោយក្រុមការងារទាំងបីក្រុមគណនេយ្យភាព ក្រុមអនុត្តថវិកា និងក្រុមស្តង់ដារគណនេយ្យ។

4. កម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈគឺជា និងនៅតែជាអភិក្រមគ្រប់ដណ្តប់កិច្ចការកែទម្រង់។ បន្ថែមពីលើការគាំទ្រពីពហុម្ចាស់ជំនួយ(MDTF) កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានទទួលការគាំទ្រ ផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដោយផ្ទាល់មួយចំនួនរួមទាំង ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA), អង្គការយូនីសេហ្វ រតនាគារសហរដ្ឋអាម៉េរិក និងមូលនិធិរូបិយវត្ថុ អន្តរជាតិ (IMF) ។

5. បើទោះបីជាមានការរីកចម្រើន និងការកើនឡើងបែបនេះក៏ដោយ ក៏នៅតែមិនគ្រប់គ្រាន់ដើម្បីឈានដល់គោលដៅប្រសិទ្ធភាព និងតម្លាភាព នៃកំណែទម្រង់ប្រទេសឲ្យស្របទៅនឹងការអភិវឌ្ឍនៅក្នុងតំបន់។ ដូច្នេះ គម្រោងទំនើបកម្មការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(PFMMP) ត្រូវបានបង្កើតឡើងនៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៣ ដើម្បីបន្តអនុវត្តឲ្យបានជោគជ័យនៃគម្រោងក្នុងដំណើរការ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគណនេយ្យភាព (PFMAP) ក្រោមហិរញ្ញប្បទានដោយ IDA ក្រោយពីបានបញ្ចប់កញ្ចប់ថវិកាពីពហុម្ចាស់ជំនួយ (MDTF) និងផ្តោតលើការធ្វើឱ្យប្រសើរឡើង គណនេយ្យភាពហិរញ្ញវត្ថុ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយប្រសិទ្ធិភាពក្នុងដំណាក់កាលទី២ នៃកម្មវិធីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

6. គោលបំណងនៃការអភិវឌ្ឍគម្រោង គឺដើម្បីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយពង្រឹង : (ក) ការកៀងគរចំណូលនិង (ខ) ដំណើរការអនុវត្តថវិកាតាមរយៈការអនុវត្តន៍ប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុ (FMIS) ផងដែរ។ ការរីកចំរើនដែលឆ្លើយតបទៅនឹងគោលបំណងដ៏សំខាន់ នឹងត្រូវបានវាស់ដោយមានការចូលរួមចំណែកអនុវត្តកម្មវិធីគន្លឹះ និងគោលដៅដែលកំណត់ចេញទៅ នៅក្នុងដំណាក់កាលទី២ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ វាតំណាងឱ្យការបន្តជំនួយរបស់ធនាគារពិភពលោក និងដៃគូរអភិវឌ្ឍន៍ក្រោមការសម្របសម្រួលពីរាជរដ្ឋាភិបាល ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់របស់ខ្លួនជាច្រើនឆ្នាំកន្លងមក។

7. PFMSC បានបង្កើតអគ្គលេខាធិការដ្ឋានអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដើម្បីជួយសម្រសម្រួលការងារប្រចាំថ្ងៃក្នុងការអនុវត្តគម្រោង រួមទាំងការធ្វើផែនការគម្រោងពិនិត្យ និងធ្វើរបាយការណ៍អនុត្តកិច្ចការងារលទ្ធកម្ម ទូទាត់ចំណាយ និងការគ្រប់គ្រងហិរញ្ញវត្ថុ។ តួនាទី និងមុខងាររបស់ GSPFMRSC មានដូចខាងក្រោម÷

- (i) គាំទ្រ និងជួយ PFMSC ក្នុងកិច្ចការរដ្ឋបាលនិង Logistic ទាំងអស់។
- (ii) ដើរតួនាទីការសម្របសម្រួលជូន PFMSC ក្នុងករណីចាំបាច់ ដូចជារៀបចំឯកសារកិច្ចប្រជុំ/ សិក្ខាសាលា / សិក្ខាសាលា ។ល។
- (iii) សម្របសម្រួលនិង ជួយអគ្គនាយកដ្ឋាន/នាយកដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅពេលដែលមានតម្រូវការដូចជា ការបង្កើត ការអនុវត្ត និងការត្រួតពិនិត្យកម្មវិធីកំណែទម្រង់នេះ។
- (iv) គាំទ្រផ្តល់ជំនួយបច្ចេកទេសដល់ អគ្គនាយកដ្ឋាន/នាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- (v) ទំនាក់ទំនងជាមួយ DPs ឬក៏មន្ត្រីសម្របសម្រួលរបស់អគ្គនាយកដ្ឋាន ឬទំនាក់ទំនងតាមបណ្តាញ (ឧ. ទំនាក់ទំនងជាមួយលេខាធិការនៃអគ្គនាយកដ្ឋាន ប្រសិនបើជាមន្ត្រីតែមួយ ដែលត្រូវធ្វើការទំនាក់ទំនង)
- (vi) ទំនាក់ទំនងជាមួយភ្នាក់ងាររដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងទៀត
- (vii) របាយការណ៍ស្តីពីការត្រួតពិនិត្យស្តីពីវឌ្ឍនភាពនៃកម្មវិធីកំណែទម្រង់(សូចនាករ និងការសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងការធ្វើការត្រួតពិនិត្យ) ដូចជាការធ្វើបច្ចុប្បន្នភាពឲ្យបានទៀងទាត់ស្តីពីការផ្តល់ជំនួយការបច្ចេកទេស PFM
- (viii) ផ្តល់យោបល់ជូន PFMSC លើសកម្មភាពបង្ការពេលដែលផែនការត្រូវបានអនុត្តខុសគោលដៅ ក៏ដូចអនុត្តការងារផ្សេងដែលបានស្នើដោយ PFMSC។

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងាកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដឹកនាំដោយអគ្គលេខាធិការ០១រូប និងមានការគាំទ្រផ្នែកបច្ចេកទេសពីអគ្គលេខាធិការរង នាយកផ្នែករដ្ឋបាលនិង ហិរញ្ញវត្ថុ មន្ត្រីជំនាញជាន់ខ្ពស់ មន្ត្រីជំនាញ មន្ត្រីលទ្ធកម្ម មន្ត្រីគណនេយ្យ មន្ត្រីថវិកា មន្ត្រីរដ្ឋបាល និងមន្ត្រីព័ត៌មានវិទ្យា ជាច្រើនរូប។

## II. ភារកិច្ច និងការទទួលខុសត្រូវ

ក. ***ស្តង់ដារបច្ចេកទេសវាយតម្លៃនៃអង្គភាពផ្តល់សេវាសាធារណៈគំរូ***

- ចូលរួមរៀបចំបច្ចុប្បន្នភាពស្តង់ដារវាយតម្លៃសេវាសាធារណៈគំរូជាមួយក្រសួងមុខងារសាធារណៈ
- សេនាធិការរបស់នាយកដ្ឋានក្នុងនាមជាសមាជិកនៃគណៈកម្មការបច្ចេកទេសវាយតម្លៃសេវាសាធារណៈគំរូ
- ចុះវាយតម្លៃក្នុងនាមជាសមាជិកនៃគណៈកម្មបច្ចេកទេសវាយតម្លៃសេវាសាធារណៈគំរូ
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារក្នុងកិច្ចដំណើរការចុះវាយតម្លៃសេវាសាធារណៈគំរូ។

## III. លទ្ធផលប្រចាំកិច្ចសន្យា

ទីប្រឹក្សាបច្ចេកទេសរបស់ **អ.គ.ហ.** ដែលស្ថិតនៅក្រោមផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងត្រួតពិនិត្យនិងវាយតម្លៃ នឹងផលិតចេញជាពីរលទ្ធផលដូចខាងក្រោម÷

| ***លទ្ធផលក្នុងឆ្នាំ*** | ***វាស់វែង*** |
|---|---|
| រៀបចំបច្ចុប្បន្នភាពស្តង់ដារវាយតម្លៃសេវាសាធារណៈគំរូ (វិទ្យាល័យ) | – សៀវភៅស្តង់ដារវាយតម្លៃ (ស្តង់ដារទី៣ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ)<br>– របាយការណ៍ចុះវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈក្នុងវិស័យអប់រំ(បឋមសិក្សា និងអនុវិទ្យាល័យ)<br>– របាយការណ៍សម្រាំងបេក្ខជនអង្គភាពផ្តល់សេវាសាធារណៈក្នុងវិស័យអប់រំ (វិទ្យាល័យ) |

## IV. របាយការណ៍

ទីប្រឹក្សាបច្ចេកទេស អ.គ.ហ. ត្រូវរាយការណ៍ពីការអនុវត្តសកម្មភាពការងារដែលទទួលបន្ទុកជូនអគ្គលេខាធិការតាមរយៈនាយកផ្នែក និងអគ្គលេខាធិការរងទទួលបន្ទុកផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងត្រួតពិនិត្យនិងវាយតម្លៃ។

## V. រយៈពេលបំពេញការងារ និងពេលវេលាបំពេញការងារ

ទីប្រឹក្សាបច្ចេកទេស អ.គ.ហ. ត្រូវបំពេញការងារជាលក្ខណៈក្រៅម៉ោង (Freelance Consultant) តាមការកំណត់របស់ អ.គ.ហ. ក្នុងរយៈពេល១២ខែ និងអាចបន្តកិច្ចសន្យាតាមភាពចាំបាច់។ ទីកន្លែងបំពេញការងារ ជាការទទួលខុសត្រូវរបស់ទីប្រឹក្សាបច្ចេកទេស។

## VI. កម្រិតវប្បធម៌ និងបទពិសោធន៍

- ត្រូវមានសញ្ញាប័ត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញហិរញ្ញវត្ថុ/ពាណិជ្ជសាស្ត្រ/សេដ្ឋកិច្ច ឬសញ្ញាប័ត្រប្រហាក់ប្រហែល
- ត្រូវមានបទពិសោធន៍យ៉ាងតិច០២ឆ្នាំ ក្នុងការងារវិស័យសេដ្ឋកិច្ចអភិវឌ្ឍ និងសេដ្ឋកិច្ចសាធារណៈ

- មានបទពិសោធន៍យ៉ាងតិច២ឆ្នាំ ក្នុងការវាយតម្លៃសេវាសាធារណៈគំរូ ជាពិសេសពាក់ព័ន្ធវិស័យអប់រំ និងវិស័យសុខាភិបាល
- ត្រូវមានបទពិសោធន៍យ៉ាងតិច០២ឆ្នាំ ក្នុងការចែករំលែកចំណេះដឹង
- ចេះសរសេរ និងនិយាយភាសាខ្មែរ និងភាសាអង់គ្លេសបានល្អ
- មានចំណេះដឹងទាក់ទងនឹងវិស័យសាធារណៈ ជាពិសេសលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា
- ត្រូវមានជំនាញប្រាស្រ័យទាក់ទង និងមានបទពិសោធន៍ក្នុងការងារជាក្រុម
- ត្រូវមានគំនិតច្នៃប្រឌិត ចូលចិត្តការងារកែទម្រង់ និងមានឆន្ទៈចូលរួមក្នុងការប្រកួតប្រជែង។